រក្សាសិទ្ធិ © ពត៌មាន :
© ២០០៩ Project WorldReach © ២០០៩ SEAN
រក្សាសិទ្ធិគ្រប់យ៉ាង

បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត ®

Project WorldReach (T&M™ ព័ន្ធកិច្ចប្រតិបត្តិការ)
Dr. George Patterson, (អ្នកនិពន្ធកម្មវិធី)
SEAN អន្តរជាតិ

អាស័យដ្ឋានសំរាប់ទាក់ទង :
Project WorldReach PWR™
474 - 800 - 15355 - 24th Ave
Surrey BC, Canada
V4A 2H9

E-mail: pwr@trainandmultiply.com
Website: http://www.trainandmultiply.com

017KH01A-01

លោកយ៉ូហាន អ្នកធ្វើពិធីជ្រមុជទឹក



កូនស្បៃរំភៅសំរាប់បង្ហាត់បង្រៀនគ្រូគង្វាល

១៧

បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត ®

T&M ™

តើលោកយ៉ូហាន អ្នកធ្វើពិធីជ្រមុជទឹក ជានរណា ?

លោកយ៉ូហាន អ្នកធ្វើពិធីជ្រមុជទឹក មិនមែនជាសាវ័កដែលបានសរសេរគម្ពីរដំណឹងល្អយ៉ូហាននោះទេ ។ លោកជាព្យាការីមួយរូប ។

លោកយ៉ូហាន អ្នកធ្វើពិធីជ្រមុជទឹក ធ្វើកិច្ចការបំរើបីយ៉ាង :

១- លោករៀបចំមនុស្សអោយអាចទទួលព្រះយេស៊ូ ពេលព្រះអង្គយាងមក ។

២- លោកធ្វើពិធីជ្រមុជទឹកថ្វាយព្រះអម្ចាស់យេស៊ូ ហើយបានណែនាំប្រាប់ប្រជារាស្ត្ររបស់ព្រះជាម្ចាស់អំពីព្រះអង្គ ។

៣- លោកជាសំឡេងបុរសម្នាក់ ដែលស្រែកឡើងនៅវាលរហោស្ថាន ដើម្បីអំពាវនាវហៅមនុស្សទាំងអស់ ឱ្យកែប្រែចិត្តគំនិតជាបន្ទាន់ ។

កំណត់ចំណាំ

© Project WorldReach © SEAN

កំណត់ចំណាំ

សេចក្តីប្រកាសរបស់លោកយ៉ូហាន គឺសំរាប់ពេលសព្វថ្ងៃនេះដែរ : *«ចូរកែប្រែចិត្តគំនិតឡើង ដ្បិតព្រះរាជ្យនៃស្ថានបរមសុខមកជិតបង្កើយហើយ !»* ។ (លូកា ២៤:៤៦-៤៨, កិច្ចការ ១១:១៨, កិច្ចការ ១៧:៣០) ។



© Project WorldReach © SEAN

តើលោកយ៉ូហាន អ្នកធ្វើពិធីជ្រមុជទឹកបានធ្វើអ្វីខ្លះ ?

លោកយ៉ូហាន អ្នកធ្វើពិធីជ្រមុជទឹក បានរៀបចំផ្លូវថ្វាយព្រះ-អម្ចាស់ ។ លោកបានស្រែកអំពាវនាវឱ្យមនុស្សកែប្រែចិត្តគំនិត ។

លោកយ៉ូហានបានធ្វើពិធីជ្រមុជទឹកអោយមនុស្សបាបរាប់ពាន់នាក់ ក្រោយពីពួកគេបានលន់តួសារភាពអំពើបាបរបស់ខ្លួនហើយ ។ ពួកគេទទួលពីធីជ្រមុជទឹក ដើម្បីបញ្ជាក់ថា ពួកគេបានកែប្រែចិត្តគំនិត ។

ពិធីជ្រមុជទឹករបស់លោកយ៉ូហានបញ្ជាក់ប្រាប់ពីការ _____។

សូមអានម៉ាថាយ ៣:១-១៧សិន មុននឹងបន្តការសិក្សាតទៅទៀត ។

☐ សូមគូសសញ្ញា «✓» នេះ ពេលអ្នកបានអានរួចហើយ ។



កំណត់ចំណាំ

© Project WorldReach © SEAN

តើការកែប្រែចិត្តគំនិតជាអ្វី ?

ការកែប្រែចិត្តគំនិត គឺជាការដែលព្រះវិញ្ញាណដ៏វិសុទ្ធជួយយើង អោយកែប្រែចិត្តគំនិត និងអាកប្បកិរិយារបស់យើងជាប្រចាំ ។ ដោយឫទ្ធានុភាពរបស់ព្រះជាម្ចាស់ យើងមិនគ្រាន់តែកែប្រែទំលាប់អាក្រក់ប៉ុណ្ណោះទេ តែយើងថែមទាំងចេះបំរើអ្នកដទៃដោយសេចក្តីស្រឡាញ់ស្មោះត្រង់ និងដោយសេចក្តីស្រឡាញ់ដែលមិនគិតពីផលប្រយោជន៍ផ្ទាល់ខ្លួនផងដែរ ។ ការអំពាវនាវអោយមនុស្សកែប្រែចិត្តគំនិត គឺជាផ្នែកមួយចាំបាច់ក្នុងការផ្សព្វផ្សាយដំណឹងល្អ ។



- អោយពួកអ្នកដែលកំពុងសិក្សាដំណឹងល្អទាំងអស់នោះជួបជុំគ្នា ដើម្បីអោយគេអាចស្គាល់គ្នាទៅវិញទៅមក ។
- ជួយមនុស្សអោយចេះអធិស្ឋាន (ដំបូង អ្នកអាចសូមអោយគេថាតាមអ្នកសិន បើចាំបាច់) ។
- ឈប់ផ្សព្វផ្សាយដំណឹងល្អដល់អ្នកដែលមិនទទួល ក្រោយពីបានផ្សព្វផ្សាយប្រាប់គេច្រើនដងរួចមក ។ សូមផ្សាយដំណឹងល្អដល់អ្នកផ្សេងទៀត ដែលយល់ព្រមទទួល ។
- យកសមាជិកក្រុមជំនុំរបស់អ្នកទៅជាមួយ ដើម្បីបង្ហាញពួកគេពីរបៀបនិយាយប្រាប់អ្នកដទៃអំពីព្រះគ្រីស្ត ។



កិច្ចការដែលត្រូវអនុវត្ត

- អធិស្ឋានទូលសូមអោយព្រះជាម្ចាស់បើកចិត្តគំនិតរបស់មនុស្ស ដើម្បីអោយគេទទួលដំណឹងល្អ ។
- បន្តផ្សព្វផ្សាយដំណឹងល្អដល់មេគ្រួសារ និងណែនាំប្រាប់ពីសេចក្តីពិតសំខាន់ៗនៃដំណឹងល្អ ឱ្យបានច្រើនដង ដល់គេម្នាក់ៗ ។ (សូមប្រើមេរៀនដំណឹងល្អបំផុត ឬវិធីផ្សព្វផ្សាយដំណឹងល្អផ្សេងទៀត ដែលបញ្ជាក់ច្បាស់លាស់ច្រើនដង អំពីអំណាចសង្គ្រោះនៃការសុគត និងការមានព្រះជន្មរស់ឡើងវិញរបស់ព្រះយេស៊ូ) ។
- អំពាវនាវហៅមនុស្សដោយសេចក្តីស្រឡាញ់ និងដោយបន្ទាន់អោយកែប្រែចិត្តគំនិតជឿ និងទទួលពិធីជ្រមុជទឹក ។
- អោយមេគ្រួសារចែកចាយពីសេចក្តីដែលគេបានរៀនដល់ក្រុមគ្រួសារ និងមិត្តភ័ក្តិរបស់គេ ព្រមទាំងអញ្ជើញពួកអ្នកទាំងនោះអោយចូលរួមក្នុងការសិក្សាផងដែរ ។ ធ្វើដូចនេះគឺដើម្បីអោយក្រុមគ្រួសារទាំងមូលអាចក្លាយទៅជាគ្រីស្តជនជាមួយគ្នាបាន ។

© Project WorldReach © SEAN

ហេតុអ្វីបានជាលោកយ៉ូហាន ធ្វើពិធីជ្រមុជទឹកថ្វាយព្រះគ្រីស្ត ?

ព្រះយេស៊ូមិនដែលប្រព្រឹត្តអំពើបាបទាល់តែសោះ ។ តើហេតុអ្វីបានជាព្រះអង្គត្រូវទទួលពិធីជ្រមុជទឹកដែរ ? តើពិធីជ្រមុជទឹកមិនមែនជាទីសំគាល់អំពីការកែប្រែចិត្តគំនិតពីអំពើបាបទេឬ ?



ព្រះគ្រីស្តមិនមែនទទួលពិធីជ្រមុជទឹក ដើម្បីធ្វើជាទីសំគាល់អំពីការកែប្រែចិត្តគំនិតពីអំពើបាបនោះទេ ។ តែព្រះអង្គបានបង្ហាញអំពីការរួមចំណែករបស់ព្រះអង្គជាមួយមនុស្សបាប តាមរយៈការជ្រមុជទឹក ។

ដូចគ្នានេះដែរ នៅពេលដែលយើងទទួលពិធីជ្រមុជទឹក យើងក៏បង្ហាញអំពីការរួមចំណែករបស់យើងជាមួយព្រះយេស៊ូគ្រីស្ត តាមរយៈការកែប្រែចិត្តគំនិត និង ជំនឿដែរ ។

យើងទទួលផលប្រយោជន៍ពីការសុគត និងការមានព្រះជន្មរស់ឡើងវិញរបស់ព្រះយេស៊ូ តាមរយៈការកែប្រែចិត្តគំនិត និងជំនឿរបស់យើងលើព្រះអង្គ ។ យើងបានទទួលការលើកលែងទោស

៥- ហេតុអ្វីបានជាត្រូវអំពាវនាវអោយមនុស្សកែប្រែចិត្តគំនិតជាបន្ទាន់ ? ពីព្រោះវាសនារបស់មនុស្ស ដែលគ្មានព្រះគ្រីស្ត គឺ : _____ ។

៦- ភ្លើងដែលឆេះមិនចេះរលត់ គឺជាកន្លែងដែលពិបាកវេទនាខ្លាំងណាស់ ។ ដើម្បីចៀសវាងកុំអោយទៅកន្លែងនោះ យើងមិនត្រូវគ្រាន់តែ « ទទួល » ព្រះគ្រីស្តប៉ុណ្ណោះទេ យើងត្រូវកែប្រែចិត្តគំនិត ដោយស្មោះត្រង់ផងដែរ ។ តើការកែប្រែចិត្តគំនិតជាអ្វី ?

- ☐ លើកដៃឡើង ពេលស្តាប់ការផ្សព្វផ្សាយដំណឹងល្អ ។
- ☐ ការកែប្រែចិត្តគំនិត និងអាកប្បកិរិយារបស់យើង ជាប្រចាំ ដើម្បីអាចរស់នៅ ដោយគោរពប្រណិប័តន៍ព្រះជាម្ចាស់ ។

៧- ដើម្បីផ្សព្វផ្សាយដំណឹងល្អអោយមានប្រសិទ្ធិភាព មិនចាំបាច់ប្រកាសសេចក្តីអធិប្បាយពិសេសវែងៗទេ ។ យើងគ្រាន់តែផ្សព្វផ្សាយអំពីព្រះគ្រីស្ត ដោយឫទ្ធានុភាពនៃ :

- ☐ ព្រះវិញ្ញាណដ៏វិសុទ្ធ ។
- ☐ សេចក្តីអធិប្បាយ ។

អំពើបាបពីព្រះជាម្ចាស់ ព្រះអំណោយទានជាព្រះវិញ្ញាណដ៏វិសុទ្ធ និងជីវិតអស់កល្បជានិច្ច ។ ពិធីជ្រមុជទឹកជាទីសំគាល់បញ្ជាក់អំពីការទាំងអស់នេះ ។

តើលោកយ៉ូហាន អ្នកធ្វើពិធីជ្រមុជទឹក អញ្ជើញមនុស្សអោយធ្វើអ្វី ?

លោកយ៉ូហាន អ្នកធ្វើពិធីជ្រមុជទឹក មិនបានអញ្ជើញមនុស្សឱ្យលើកដៃឡើងដើម្បី «ទទួល» ព្រះគ្រីស្តទេ ។ លោកក៏មិនបានអញ្ជើញពួកគេ «អោយមកខាងមុខ» ដែរ ។ លោកក៏មិនបានអញ្ជើញគេអោយធ្វើអ្វីទាំងអស់ ។ លោកបានបង្គាប់គេឱ្យកែប្រែចិត្តគំនិតចេញពីអំពើបាបរបស់ពួកគេ ។ ពេលដែលពួកគេបានកែប្រែចិត្តគំនិត លោកយ៉ូហានក៏បានធ្វើពិធីជ្រមុជទឹកអោយពួកគេភ្លាមដែរ ។

ព្រះយេស៊ូគ្រីស្តបានបញ្ជាអោយមនុស្សកែប្រែចិត្តគំនិត ។ សាវ័ករបស់ព្រះអង្គបានធ្វើពិធីជ្រមុជទឹកឱ្យអ្នកដែលកែប្រែចិត្តគំនិត ។ ពួកសាវ័កក៏បានប្រកាសព្រះបន្ទូលអំពីការកែប្រែចិត្តគំនិតដែរ ។ នៅថ្ងៃបុណ្យថ្ងៃទីហាសិប លោកពេត្រុសសិលាបានប្រកាសថា÷

ការប្រឡង (សំនួរសង្ខេបមេរៀន)

១- ភារកិច្ចសំខាន់របស់លោកយ៉ូហាន អ្នកធ្វើពិធីជ្រមុជទឹក គឺហៅមនុស្សអោយកែ _____ ។

២- មនុស្សដែលបានកែប្រែចិត្តគំនិត និងលន់តួសារភាពអំពើបាបរបស់ខ្លួន បានទទួលពិ _____ ភ្លាម ពីលោកយ៉ូហាន ។

៣- ព្រះអម្ចាស់យេស៊ូមិនដែលធ្វើបាបទាល់តែសោះ នៅក្នុងជីវិតរបស់ព្រះអង្គ ។ យោងទៅតាមព្រះបន្ទូលរបស់ព្រះអង្គ នៅក្នុង ម៉ាថាយ ៣ ហេតុអ្វីបានជាព្រះអង្គត្រូវទទួលពិធីជ្រមុជទឹកដែរ ?

☐ ដើម្បីចូលរួមចំណែកជាមួយនឹងយើង ។

☐ ដើម្បីធ្វើតាមទំនៀមទំលាប់របស់ពួកយូដា ។

៤- ការអំពាវនាវរបស់ព្រះគម្ពីរចំពោះមនុស្សបាបទាំងអស់ គឺ កែ _____ និងទទួលពិ _____ ក្នុងព្រះនាមព្រះគ្រីស្ត ។

© Project WorldReach © SEAN

«សូមបងប្អូនកែប្រែចិត្តគំនិត ហើយម្នាក់ៗត្រូវទទួលពិធីជ្រមុជទឹក ក្នុងព្រះនាមព្រះអម្ចាស់យេស៊ូគ្រីស្តទៅ ដើម្បីអោយព្រះជាម្ចាស់ លើកលែងទោសបងប្អូនអោយរួចពីបាប ហើយបងប្អូននឹងទទួល ព្រះវិញ្ញាណដ៏វិសុទ្ធ ដែលជាអំណោយទានរបស់ព្រះជាម្ចាស់» ។

(កិច្ចការ ២:៣៨)

នៅថ្ងៃនោះ មានមនុស្សប្រមាណបីពាន់នាក់ធ្វើតាមពាក្យរបស់ លោកពេត្រុស ហើយបានទទួលពិធីជ្រមុជទឹក ។

ការដែលគ្រាន់តែហៅមនុស្សអោយទទួលព្រះគ្រីស្ត មិនទាន់គ្រប់ គ្រាន់នៅឡើយទេ ។ ព្រោះការធ្វើដូចនេះ អាចនាំអោយគេធ្វើការ សំរេចចិត្តឥតបានការ ។ «ការទទួល» ព្រះគ្រីស្តគ្មានប្រយោជន៍ អ្វីឡើយ បើគ្មានការកែប្រែចិត្តគំនិត និងជំនឿនោះ ។

ដើម្បីបញ្ជាក់ថា មនុស្សពិតជាមានជំនឿដ៏ស្មោះអស់ពីចិត្តចំពោះ ព្រះគ្រីស្តមែន យើងត្រូវហៅគេឱ្យកែ _____ និងទទួលពិ _____ ។

លោកយ៉ូហានជាសំលេងបុរសម្នាក់ ដែលស្រែកនៅវាល រហោស្ថាន ហើយលោកនៅតែអំពាវនាវហៅយើងរហូត ។ សព្វថ្ងៃនេះ លោកនៅតែអំពាវនាវហៅយើងជាបន្ទាន់ដដែល ។

ព្រះជាម្ចាស់មិនបានអញ្ជើញយើងអោយទទួលពិធីជ្រមុជទឹកទេ **តែព្រះអង្គបង្គាប់យើង !**

លោកយ៉ូហានបានប្រកាសដោយឫទ្ធានុភាពរបស់ព្រះជាម្ចាស់ ។ លោកជាអ្នកនាំសាររបស់ព្រះអង្គ ។ យើងក៏ជាអ្នកនាំសាររបស់ ព្រះជាម្ចាស់ដែរ ។ ដូច្នេះ យើងត្រូវប្រកាសព្រះបន្ទូលរបស់ព្រះ-ជាម្ចាស់ ដោយអំណាចរបស់ព្រះអង្គ ដូចលោកយ៉ូហានដែរ ។

យើងត្រូវហៅមនុស្សអោយកែ _____ និងទទួលជីវិតថ្មីក្នុងអង្គព្រះគ្រីស្ត ។ យើងត្រូវធ្វើកិច្ចការនេះជា **បន្ទាន់បំផុត !**

តើពិធីជ្រមុជទឹកបញ្ជាក់អំពីអ្វីខ្លះ ?

១- ការកែប្រែចិត្តគំនិត និងជំនឿរបស់យើងលើព្រះអម្ចាស់យេស៊ូ ។

២- ការរួមចំណែកជាមួយព្រះយេស៊ូគ្រីស្តដែលបានសុគត និងមានព្រះជន្មរស់ឡើងវិញ ដើម្បីអោយយើងបានព្រះជាម្ចាស់លើកលែងទោស ទទួលបានព្រះវិញ្ញាណដ៏វិសុទ្ធ និងជីវិតអស់កល្ប ។

ការដែលគ្រាន់តែទទួលព្រះគ្រីស្ត មិនទាន់គ្រប់គ្រាន់នៅឡើយទេ។ ព្រះគម្ពីរបានចែងថា÷ សូមបងប្អូនកែប្រែចិត្តគំនិត ហើយម្នាក់ៗត្រូវទទួលពិធីជ្រមុជទឹក (កិច្ចការ ២:៣៨) ។ បើមនុស្សមិនកែប្រែចិត្តគំនិតទេ នោះគេមិនអាចទទួលការសង្គ្រោះបានឡើយ ។ ពិធីជ្រមុជទឹកបញ្ជាក់ពីការកែប្រែចិត្តគំនិតរបស់យើង ។

យើងបានសង្គ្រោះដោយសារជំនឿ គឺជំនឿនេះហើយ ដែលនាំឱ្យជីវិតរបស់យើងមានការផ្លាស់ប្តូរ ។ យើងបានកើតជាថ្មី នៅពេលដែលព្រះគ្រីស្តប្រទានជីវិតថ្មីដល់យើង តាមរយៈព្រះវិញ្ញាណដ៏វិសុទ្ធ ។

ឥឡូវនេះ យើងនឹងសិក្សា ម៉ាថាយ ៣:១-១៧ សាឡើងវិញ ។

លោកយ៉ូហានបានរៀបចំបណ្តាជន ដោយបង្គាប់គេអោយកែ_____ និងទទួលពិ_____ ។

ពិធីជ្រមុជទឹក គឺជាទីសំគាល់អំពីការកែប្រែចិត្តគំនិត និងអំពីជីវិតថ្មីរបស់យើងក្នុងអង្គព្រះគ្រីស្ត ។

ពួកអ្នកដែលបានលន់តួសារភាពអំពើបាបរបស់ខ្លួន ក៏បានទទួលពិធីជ្រមុជទឹកពីលោកយ៉ូហាន ។ នៅពេលដែលមនុស្សជឿលើព្រះគ្រីស្តហើយ គេមិនចាំបាច់រំលឹកពីអំពើបាបគ្រប់យ៉ាង ដែលគេបានប្រព្រឹត្ត ដើម្បីលន់តួសារភាពនោះទេ ។ ពួកគេគ្រាន់តែទទួលស្គាល់ថាគេជាមនុស្សមានបាប ហើយទុកចិត្តថាព្រះគ្រីស្តលើកលែងទោសអោយគេ និងប្រទានជីវិតថ្មីអោយគេ នោះគ្រប់គ្រាន់ហើយ ។

កំណត់សំគាល់ :

មនុស្សខ្លះបានទទួលពិធីជ្រមុជទឹកហើយ ប៉ុន្តែ ក្រោយមក គេបានងាកចេញពីព្រះជាម្ចាស់ ។ បើសិនជាអ្នកទាំងនោះលន់តួសារភាព កែប្រែចិត្ត និងទទួលជឿពិតប្រាកដឡើងវិញ សូមទទួលយកពួកគេវិញ តាមរបៀបរបបក្រុមជំនុំរបស់អ្នកចុះ ។



ហេតុអ្វីបានជាលោកយ៉ូហាន និងពួកសាវ័កអំពាវនាវ ហៅមនុស្សអោយកែប្រែចិត្តគំនិតជាបន្ទាន់ដូច្នេះ ?

លោកយ៉ូហានមានប្រសាសន៍ទៅកាន់ពួកគេថា៖ *«ខ្ញុំធ្វើពិធីជ្រមុជអ្នករាល់គ្នាក្នុងទឹក ដើម្បីអោយអ្នករាល់គ្នាបានកែប្រែចិត្តគំនិត ប៉ុន្តែ លោកដែលមកក្រោយខ្ញុំ លោកមានកំឡាំងខ្លាំងជាងខ្ញុំ ។ ខ្ញុំមានឋានៈទាបណាស់ សូម្បីតែដោះស្បែកជើងជូនលោក ក៏មិនសមនឹងឋានៈដ៏ខ្ពង់ខ្ពស់របស់លោកផង ។ លោកនឹងធ្វើពិធីជ្រមុជអោយអ្នករាល់គ្នាក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ និង ដោយភ្លើងវិញ ។ លោកកាន់ចង្អេរ លោកសំអាតលានបោកស្រូវ អុំស្រូវយកគ្រាប់ល្អរបស់លោកប្រមូលដាក់ជង្រុក រីឯសំដីវិញ លោកនឹងទុកក្នុងភ្លើងដែលឆេះពុំចេះរលត់ឡើយ »* (ម៉ាថាយ ៣:១១-១២) ។

ការដែលត្រូវធ្វើជាបន្ទាន់បំផុត គឺគេចចេញពីភ្លើងនៃការជំនុំជំរះរបស់ព្រះជាម្ចាស់ ដែលនឹងមកដល់ ។ យើងត្រូវធ្វើអោយអ្នកមិនជឿដឹងពីគ្រោះថ្នាក់ ដែលបណ្តាលមកពីអំពើបាបរបស់ខ្លួន ។

© Project WorldReach © SEAN

ចូរយើងប្រកាសដោយជឿជាក់ និងជាបន្ទាន់ ដូចលោកយ៉ូហានដែរ ។ នេះជារបៀបប្រកាសដ៏សំខាន់ ដែលយើងត្រូវធ្វើតាម ។

សំលេងរបស់លោកយ៉ូហាននៅតែស្រែកហៅពីទីរហោស្ថានមកថា÷*«ចូរកែប្រែចិត្តគំនិតឡើង !»* ។ អ្នកនាំសាររបស់ព្រះជាម្ចាស់ម្នាក់នេះ បានស្រែកអំពាវនាវដូចនេះឥតឈប់ឈរ ។ លោករៀបចំយើងអោយរកឃើញជីវិតថ្មីក្នុងព្រះអម្ចាស់យេស៊ូគ្រីស្ត ។



យើងត្រូវផ្សព្វផ្សាយដំណឹងល្អជារៀងរាល់ថ្ងៃ ដល់សាច់ញាតិមិត្តភក្តិ និងអ្នកជិតខាងរបស់យើង ។ បើយើងស្រឡាញ់ពួកគេ យើងត្រូវធ្វើអ្វីៗដែលអាចនាំពួកគេអោយបានជឿលើព្រះគ្រីស្ត ។

ដើម្បីផ្សព្វផ្សាយដំណឹងល្អអោយមានប្រសិទ្ធិភាព យើងមិនបាច់ប្រកាសសេចក្តីអធិប្បាយពិសេសៗវែងឆ្ងាយទេ ។ យើងគ្រាន់តែនិយាយប្រាប់អោយគេស្គាល់ដឹងអំពីព្រះគ្រីស្ត ដោយពឹងអាងលើបុទ្ធានុភាពនៃព្រះវិញ្ញាណដ៏វិសុទ្ធបានហើយ ។



© Project WorldReach © SEAN